# សិក្ខាសាលាពិគ្រោះយោបល់សាធារណៈលើ
# កម្មវិធីព្រៃឈើជាតិកម្ពុជា

## I.សេចក្តីផ្តើមទូទៅនៃអង្គសិក្ខាសាលា

ក្នុងខែ មិនា ឆ្នាំ២០០៩ កន្លងមកថ្មីៗនេះ ជាមួយជំនួយថវិកាពីអង្គការ Danida/Dfid/NZAid និង NFP Facility/FAO រដ្ឋបាលព្រៃឈើ បានទទួលជោគជ័យលើការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកម្មវិធីព្រៃឈើជាតិនៅតាមភូមិភាគព្រៃឈើទាំងបួនក្នុងទូទាំងប្រទេស។ ដើម្បីធ្វើឱ្យសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ មានខ្លឹមសារកាន់តែប្រសើរ អាចអនុវត្តបានប្រកបដោយ ប្រសិទ្ធិភាព និង ឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន រដ្ឋបាលព្រៃឈើនឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់សាធារណៈមួយទៀតនៅថ្នាក់ក្រោមជាតិ ដែលនឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ២០០៩** នៅសណ្ឋាគារ ភ្នំប្រុស នាទីក្រុងកំពង់ចាម ខេត្តកំពង់ចាម។

សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈនេះ មានគោលបំណងដើម្បីបង្កើនការយល់ដឹងនិង ប្រមូលយកនូវមតិ កែលំអពីបណ្តាភាគីពាក់ព័ន្ធលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ និង កម្មវិធីវិនិយោគសំរាប់វិស័យព្រៃឈើ។ នៅថ្ងៃទី ១ នៃអង្គសិក្ខាសាលានឹងមានបទបង្ហាញ និងការចាប់អារម្មណ៍ពីតំណាងភាគីពាក់ព័ន្ធនានា ហើយនៅថ្ងៃទី ២ នឹងមានការពិភាក្សាលើឯកសារទាំងពីរខាងលើ ។ រដ្ឋបាលព្រៃឈើនឹង អញ្ជើញអ្នកចូលរួមសរុបចំនួន ១៥០ នាក់ មកពីក្រសួងមន្ទីរពាក់ព័ន្ធ សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន វិស័យឯកជន ព្រះសង្ឃ អ្នកសារព័ត៌មាន អង្គការក្រៅរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍នានា។

សិក្ខាកាមទាំងអស់អស់ ត្រូវបានអញ្ជើញចូលរួមក្នុងនាមតំណាងអោយស្ថាប័នរបស់ខ្លួន ដូចនេះមុននឹងមកចូលរួម សិក្ខាកាមទាំងអស់គួរធ្វើការពិភាក្សាលើបញ្ហានិងវិធានបទ នៃអង្គសិក្ខាសាលាជាមួយស្ថាប័នរបស់ខ្លួនជាមុន ។ មតិយោបល់ពីសិក្ខាកាមទាំងអស់នឹងត្រូវបានកត់ត្រា យកទៅពិចារណាដើម្បីសរិតសំរាំងដាក់បញ្ចូលក្នុងឯកសារព្រាងកម្មវិធីព្រៃឈើជាតិ ។ អ្នករៀបចំកម្មវិធីប្រាថ្នាចង់បាន គំនិតយោបល់ដែលឆ្លុះបញ្ចាំងនូវគោលជំហរនៃស្ថាប័នរបស់សិក្ខាកាម ជាជាងគំនិតផ្ទាល់ខ្លួនរបស់សិក្ខា កាម។ អ្នករៀបចំសិក្ខាសាលា មានបំណងអោយការពិភាក្សារួមក្នុងពេលដំណើរអង្គសិក្ខាសាលា ដោយមានការចូលរួមគ្រប់ ស្ថាប័នពាក់ព័ន្ធ មុននឹងឈានដល់ការបញ្ចប់ការចងក្រងកម្មវិធីនេះ។





## II. សេចក្តីសង្ខេបនៃប្រវត្តិកម្មវិធីព្រៃឈើ

កម្មវិធីព្រៃឈើជាតិ គឺជាក្របខណ្ឌរួមនៃការងារព្រៃឈើទាំងមូល ។ កម្មវិធីនេះចង្អុលបង្ហាញនូវគោលបំណង និង វិធីសាស្ត្រនៃការរៀបចំផែនការ រៀបចំកម្មវិធីការងារ និងការអនុវត្តន៍លើសកម្មភាពការងារ ក្នុងវិស័យព្រៃឈើ ។ កម្មវិធីព្រៃឈើជាតិ មានលក្ខណៈខុសគ្នា ពីប្រទេសមយយទៅប្រទេសមួយទៀត អាស្រ័យលើវិធីសាស្ត្រចងក្រង ប៉ុន្តែមានធាតុសំខាន់ ៧ ដូចគ្នា ។

មានព្រឹត្តការណ៍ពិភពលោកជាច្រើន ដែលនាំអោយបានការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ ក្នុងបណ្តាប្រទេសជាសមាជិក នៃអង្គការសហប្រជាជាតិ ។ ព្រឹត្តការណ៍ទាំងនេះចាប់ផ្តើមឡើងពី របៀបវារៈ ២១ នៃ UNCFD និង ក្រោយមកទៀតមានបណ្តា វេទិការអន្តរដ្ឋាភិបាលស្តីពីព្រៃឈើ ដែលវេទិការទាំងនេះអំពាវនាវ អោយមានការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ ។ ជាការឆ្លើយតប នឹងការអំពាវនាវនេះ កិច្ចប្រជុំគណៈកម្មការសំរបសំរួលរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយនៃប្រទេសកម្ពុជា កាលពីខែ មិថុនា ឆ្នាំ ២០០៦ បានលើកឡើងថា" ជាទូទៅយើងជឿជាក់ថា មានការចាំបាច់ អោយមានក្របខណ្ឌគោលនយោបាយ និងផែនការជាតិរយៈពេលវែងមួយ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ក្នុងវិស័យព្រៃឈើ " ។ ស្របពេលជាមួយគ្នានេះ ក្រុមការងារបច្ចេកទេសស្តីពី ព្រៃឈើ និង បរិស្ថាន បានយកចិត្តទុកដាក់ និងសង្កត់ធ្ងន់លើការអភិវឌ្ឍន៍កម្មវិធីព្រៃឈើ ហើយមកដល់ពេលនេះថវិកាត្រូវបានគៀងគរប្រមូលសំរាប់ការងារនេះ ។

## III. ដំណើរការចងក្រងកម្មវិធីព្រៃឈើជាតិកម្ពុជា :

រដ្ឋបាលព្រៃឈើបានប្តេជ្ញាចិត្ត ដើរតួនាទីជាស្ថាប័ននាំមុខគេក្នុងដំណើរការអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ ។ មានការយល់ស្របគ្នាថា ការអភិវឌ្ឍន៍ព្រៃឈើជាតិ ដែលមានលក្ខណៈភាពជាម្ចាស់ គឺមានសារៈសំខាន់ណាស់ សំរាប់ដំណើរទៅមុខ នៃវិស័យព្រៃឈើ កម្ពុជា ។ ឯកឧត្តមប្រធាន និង ឯកឧត្តមអនុប្រធានរដ្ឋបាលព្រៃឈើ មានការគាំទ្រយ៉ាងមុតមាំ ដល់ដំណើរកម្មវិធីព្រៃឈើនេះ ។

### *ការបង្កើត និង សមាជិកភាព នៃក្រុមការងារកម្មវិធីព្រៃឈើជាតិ*

យោងតាមលទ្ធផលនៃ អនុសាសន៍ពីសិក្ខាសាលាលើកដំបូង នៃកម្មវិធីនេះ សមាជិក និងដៃគូរត្រូវបានគេកំណត់បាននៅក្នុងសិក្ខាសាលាលើកទី ២ ដែលក្រោយមកបានប្រមូលផ្តុំ បង្កើតបានជាក្រុមការងារកម្មវិធីព្រៃឈើជាតិ ។ ក្រុមការងារនេះ គឺជាក្រុមារងារអន្តរវិស័យ ហើយមានសមាជិក ជាតំណាងមកពីភាគីពាក់ព័ន្ធនានារួមមានក្រសួងពាក់ព័ន្ធវិស័យឯកជន អង្គការក្រៅរដ្ឋភិបាល មហាវិទ្យាល័យអន្តរជាតិ និងដៃគូរអភិវឌ្ឍន៍នានា។ ក្រុមការងារនេះគាំទ្រ និងចូលរួមដោយផ្ទាល់ ក្នុងដំណើរការអភិវឌ្ឍន៍ កម្មវិធី ។

### *កម្មវិធីការងារ និងអនុក្រុមការងារ*

ក្រុមការងារកម្មវិធីព្រៃឈើជាតិ បានបង្កើតអនុក្រុមការងារចំនួន០៦ ដែលក្រុមនិមួយ ៗ ទទួលខុសត្រូវ ចងក្រងកម្មវិធីការងារចំនួនមួយ ។ ក្រុមការងារបានឯកភាព ចងក្រងកម្មវិធីចំនួន៦ ដូចខាងក្រោម :

១. កម្មវិធី កំនត់ព្រំប្រទល់ ការចាត់ថ្នាក់ ការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

២. កម្មវិធីការគ្រប់គ្រងធនធានព្រៃឈើ និងអភិរក្ស

៣. កម្មវិធីការពង្រឹងច្បាប់ និងអភិបាលកិច្ច

៤. កម្មវិធីសហគមន៍ព្រៃឈើ

៥. កម្មវិធីកសាងសមត្ថភាព និងអភិវឌ្ឍន៍ការស្រាវជ្រាវ

៦. កម្មវិធីហិរញ្ញវត្ថុព្រៃឈើប្រកបដោយនិរន្តរភាព

## IV. **ក្របខណ្ឌយុទ្ធសាស្ត្រ**

ឯកសារក្របខណ្ឌយុទ្ធសាស្ត្រ ដើរតួនាទីជាឈ្នាប់តភ្ជាប់ កម្មវិធីការងារទាំងអស់ខាងលើ ។ ឯកសារនេះបានរៀបរាប់អំពីការងារអាទិភាពនានាសំរាប់រយៈពេល ២០ឆ្នាំ ខាងមុខរបស់កម្មវិធីព្រៃឈើជាតិ ដែលរយៈពេលអនុវត្តដូចគ្នា នឹងកម្មវិធីការងារទាំង៦ ខាងលើដែរ។ ឯកសារក្របខ័ណ្ឌ យុទ្ធសាស្ត្រនេះ នឹងត្រូវធ្វើបច្ចុប្បន្ន កែសំរួលក្នុងរយៈពេល ០៥ឆ្នាំម្តង តាមរយៈការធ្វើពិគ្រោះយោបល់គ្រប់ភាគីពាក់ព័ន្ធ ពិសេស សហគមន៍មូលដ្ឋាន ។

មាតិកាសំខាន់ ៗ នៅក្នុងសេចក្តីព្រាង ឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្ររួមមានៈ

- ការផ្តល់និយមន័យ ច្បាស់លាស់លើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព និងការគាំទ្រ ជំរុញអោយមានការគ្រប់គ្រងព្រៃឈើស្របតាមគោលការណ៍ទាំងនេះ ។
- មានការវិភាគបញ្ហាថា តើអ្វីខ្លះ ដែលចំណុចខ្វះខាត ក្នុងការគ្រប់គ្រងព្រៃឈើ
- យុទ្ធសាស្ត្រសំខាន់ ៗ ដើម្បីដោះស្រាយបញ្ហាទាំងនេះតាមរយៈអភិបាលកិច្ចល្អ។ យុទ្ធសាស្ត្រសំខាន់ ១ នេះគឺការបង្កើនការចូលរួម ពង្រឹងការអនុវត្តន៍ច្បាប់ បង្កើតកិច្ចសហប្រតិបត្តិការ និង សំរបសំរួលរវាងវិស័យពាក់ព័ន្ធទាំងអស់ ។

សេចក្តីព្រាងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រស្នើផ្តល់ជាអនុសាសន៍សំរាប់ការគ្រប់គ្រងព្រៃឈើនាពេលអនាគតដូចខាងក្រោម :

- ផ្តោតលើការបង្កើនប្រាក់ចំណូល ដែលបានលើព្រៃឈើសំរាប់សហគមន៍មូលដ្ឋាន និង សំរាប់រដ្ឋាភិបាល ដោយធ្វើយ៉ាងណាអាចថែរក្សាព្រៃឈើប្រកបដោយនិរន្តភាព និង មានការគោរពដល់សិទ្ធិប្រពៃណីរបស់សហគមន៍មូលដ្ឋាន។
- កែច្នៃផលិតផលឈើសំរាប់ទីផ្សារ ដែលផ្តល់តំលៃខ្ពស់ ( ផលិតផលឈើដែលមានវិញ្ញាប័ណ្ណបត្រ អនុផលព្រៃឈើ ដែលកែច្នៃរួច ទីផ្សារកាបោនព្រៃឈើ ) ដែលទីផ្សារទាំងនេះតំរូវអោយមានការគ្រប់គ្រងផលអនុផលព្រៃឈើអោយមាននិរន្តភាព និងមានការបញ្ជាក់ច្បាស់លាស់។
- អភិវឌ្ឍន៍ និងអនុវត្តកម្មវិធីសំរាប់ការងារសហគមន៍ព្រៃឈើ សំរាប់ការពង្រឹងការអនុវត្តន៍ច្បាប់ និង អភិបាលកិច្ចការចាត់ថ្នាក់ កំណត់ព្រំប្រទល់ ប្រព័ន្ធគ្រប់គ្រង និងអភិរក្ស វិញ្ញាបនប័ត្រព្រៃឈើ និងការពង្រឹងសមត្ថភាព និងកម្មវិធីការងារសំខាន់ ៗ ទៀត។

### ➪ ចំណុចដែលត្រូវលើកយកមកពិភាក្សាក្នុងអង្គសិក្ខាសាលា

- តើអ្វីដែលជាឧបសគ្គចំបង រាំងស្ទះដល់ការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ហើយថាតើគួរធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហាទាំងនេះ ។
- ព្រៃឈើកំពុងរងការគំរាមកំហែង ពីការចាប់រំលោភយកដីព្រៃ។ តើព្រៃឈើគួរត្រូវបានគ្រប់គ្រងបែបណា អោយប្រសើរជាងនេះ។
- វិធីមួយក្នុងការបង្កើនប្រាក់ចំណូលពីព្រៃឈើ គឺការប្រមូលថ្លៃសួយសារ សេវាកម្ម បរិស្ថាន ( អ្នកក្រុងបង់លុយសំរាប់ប្រើប្រាស់ទឹកស្អាតពីព្រៃឈើ ។ តើប្រទេសកម្ពុជាអាចធ្វើបែបនេះបានឬទេ ? បើបាន តើពេលណា ហើយគួរធ្វើយ៉ាងដូចម្តេច ?

- តើអ្នកអាចស្នើជាយន្តការសំរាប់ការបែងចែកផលប្រយោជន៍ពីព្រៃឈើដោយសមធម៌បានទេ (រវាងរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងក្រុមហ៊ុន)
- តើកិច្ចការអ្វីខ្លះដែលត្រូវធ្វើ ក្នុងវិស័យសិក្សាធិការ ពិសេសលើមុខវិជ្ជាការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីគាំទ្រដល់គោលដៅនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តភាព ?

## ➪ ចំណុចក្នុងសេចក្តីព្រាងកម្មវិធី វិនិយោគសំរាប់វិស័យព្រៃឈើ

***វិធានបទ "១"***

ការគណនាដំបូងបានប៉ាន់ប្រមាណឃើញនូវចំនួនថវិកាសំរាប់អនុវត្តកម្មវិធីទាំងប្រាំដូចខាងក្រោម ។ តើអ្នកយល់ឃើញ យ៉ាងណា ?

| ការចំណាយសំរាប់កម្មវិធី | USD (លាន) |
|---|---|
| ១.ការបោះបង្គោលព្រំ | ៥៣,៦ |
| ២.ការគ្រប់គ្រង និងអភិរក្សការចំណាយសំរាប់កម្មវិធី | ៦ |
| ៣. ពង្រឹងការអនុវត្តន៍ច្បាប់ និងអភិបាលកិច្ច | ៣ |
| ៤. សហគមន៍ព្រៃឈើ | ៥,៥ |
| ៥. ការពង្រឹងសមត្ថភាព និងការស្រាវជ្រាវ | ២,៨ |
| សរុប | ៧០,៩ |

***វិធានបទ "២"***

តើក្នុងការងារអទិភាពអ្វីខ្លះ ដែលអ្នកចង់អោយរដ្ឋាភិបាលធ្វើក្នុងវិស័យព្រៃឈើដើម្បី:

- "២.១" ប្រមូលប្រាក់ចំណូលពីអាជីវកម្មឈើមូល ដែលគ្រប់គ្រងដោយរដ្ឋាភិបាល
- "២.២" ការបណ្តាក់ទុនទៅក្នុង និងការប្រមូលប្រាក់ចំណូលពីការលក់កាបោនព្រៃឈើក្រោមយន្តការ REDD
- "២.៣" បណ្តាក់ទុន និងប្រមូលប្រាក់ចំណូលពីសម្បទានបែបអភិរក្ស
- "២.៤ " ដាក់អោយដេញថ្លៃការងារមួយចំនួនដូចជា : ការបោះបង្គោលព្រំ ការសិក្សាស្រាវជ្រាវ ការដាំដុះថ្នាលបណ្តុះកូនឈើដោយមានការត្រួតពិនិត្យដោយស្ថាប័នឯករាជ្យ ដើម្បីសន្សំថវិកា និងបង្កើនប្រសិទ្ធិភាពការងារ (នៅបណ្តាបស្ចឹមប្រទេស ការងារទាំងនេះត្រូវបានប្រគល់អោយឯកជនជាអ្នកធ្វើ ដោយរដ្ឋាភិបាលផ្តោតតែលើការងាររដ្ឋបាលសាធារណៈ ការពង្រឹងការអនុវត្តន៍ច្បាប់ ការជួយលើកកំពស់ការយល់ដឹង ការបណ្តុះបណ្តាល និងការតាមដានត្រួតពិនិត្យ) ។

ចូរពិភាក្សា និង ផ្តល់ពិន្ទុ ដល់ការងារអាទិភាពនិមួយ ៗ ខាងលើ ។

**សេចក្តីព្រាងឯកសារក្របខ័ណ្ឌយុទ្ធសាស្រ្ត និងកម្មវិធីទាំងអស់មានដាក់ជូនក្នុងគេហទំព័រ http://www.twgte.org/nfp/**